ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះឈើទាលធំ

## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ កោះឈើទាលធំ |
| ភូមិ | ៖ កោះឈើទាលធំ |
| ឃុំ | ៖ ព្រះរំកិល |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កោះឈើទាលធំ រយៈពេល ៣ ឆ្នាំ(២០២០ - ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ កោះឈើទាលធំ |
| ភូមិ | ៖ កោះឈើទាលធំ |
| ឃុំ | ៖ ព្រះរំកិល |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី៖ ........ ៤

ឃ.២.ប្រភេទវារីសត្វ៖ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៥

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៦

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៧

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៧

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ៩

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ៩

ឃ.៣. ការងារគ្រប់គ្រង ........ ១០

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០

ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១១

ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១១

ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២

ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១២

ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១២

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោមៈ ........ ១៣

ច.យុទ្ធសាស្ត្រ ........ ១៣

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះឈើទាលធំ រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)** ........ ១៤

**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ** (២០២០ - ២០២២) ........ ២០

# ផែនការ[redacted]ប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទកោះឈើទាលធំ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ២០០០ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិកោះឈើទាលធំ ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៣៦៥នាក់ ស្រីចំនួន១៦៩នាក់ ស្មើនឹង១១២គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០២នាក់។ សហគមន៍នេសាទកោះឈើទាលធំ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក-សហគមន៍នេសាទនេះ បានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជា ការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងការរៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ព្រៃលិចទឹកដួលរលំច្រើន ត្រីថយចុះគ្រប់ប្រភេទ ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទ ទឹកឡើងចុះមិនទៀងទាត់ ទឹកទន្លេមានស្លែច្រើនជាដើម

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋប្រជាជនចំណាកស្រុកច្រើន ខ្វះប្រភពទឹកធ្វើស្រែ ដោយសារគ្មានទឹកភ្លៀងគ្រប់គ្រាន់ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផល ផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ អាកាសធាតុក្តៅខ្លាំង ដាំដំណាំមិនទទួលបានទិន្នផលច្រើន

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ឧបករណ៍ឆក់ និងប្រើសារជាតិពុល) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល ច្បាប់ស្តីពីតំបន់ការពារ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។

## ២.អំពី[redacted]ជាសា[redacted] និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិកោះឈើទាលធំ សរុប៥៣៦នាក់ ស្រី២៧៩នាក់ ស្មើ១១៩គ្រួសារ ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិកោះឈើទាលធំ មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារ/ស្ត្រីមេម៉ាយមាន០៣នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០៤នាក់ ស្រី០៤នាក់
- ចំនួនចាស់ជរាមាន០៣នាក់ ស្ត្រី០៣នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន៤០៦នាក់ ស្រី២០២នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៧៥នាក់ ស្ត្រី៤០នាក់ កម្រិតអនុវិទ្យាល័យចំនួន០១នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន:

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន១១១គ្រួសារ
- អ្នកធ្វើស្រែចំនួន៤៦គ្រួសារ ដែលមានទំហំដីចំនួនសរុប ៦២ ហិកតា
- ធ្វើចំការចំនួន២៥ គ្រួសារ ដែលមានទំហំដីចំនួនសរុប៤.៥ហិកតា (ស្រូវ.ពោត.ដំឡូង.ថ្នាំជក់...)
- ដាំបន្លែជាលក្ខណៈគ្រួសារ១០១គ្រួសារ ដែលមានទំហំសរុប ០.៦ហិកតា
- លក់ដូរជាអាជីពចំនួន ០៦ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ស្មើ ៩០%
- ពេទ្យសត្វ ០២ គ្រួសារ
- ឆ្មបភូមិ ០២ នាក់
- ចំណាកស្រុកទៅក្រៅប្រទេស (ប្រទេសថៃ ៣៣ នាក់ ស្ត្រី១៧នាក់)
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន១១២ គ្រួសារ ក្នុងនោះរួមមានប្រហុក ត្រីប្រៃ (មួយគ្រួសារអាចផលិតបានពី១៥ គីឡូក្រាមទៅ ២៦គីឡូក្រាមក្នុង១ឆ្នាំ)

## ៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍កោះឈើទាលធំ ជាដែននេសាទសាធារណៈរបស់រដ្ឋ កន្លែងនេសាទសហគមន៍កោះឈើទាលធំ មានទំហំ ៣២៩ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង ពាក់កណ្តាលទន្លេជាប់ព្រំប្រទល់ប្រទេសឡាវ
- ខាងត្បូងទល់នឹង ក្បាលកោះឈើទាលតូច និងកោះបន្ទាយ ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ
- ខាងកើតទល់នឹង ពាក់កណ្តាលទន្លេជាប់ព្រំប្រទល់សហគមន៍នេសាទភូមិ អូរស្វាយ ឃុំអូរស្វាយ
- ខាងលិចទល់នឹង ច្រាំងខាងកើតកោះបន្ទាយជាប់ដែនសហគមន៍នេសាទភូមិកោះលូ ។

ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទកោះឈើទាលធំ មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានប្រឡាយចំនួន០៣ អូរចំនួន០២ និងអន្លង់ចំនួន០៥។

ខ.១.ទន្លេ

| ឈ្មោះទន្លេ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ១២.០០០ | ពេញមួយឆ្នាំ |

ខ.២.អូរ

| ឈ្មោះអូរ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| អូរតាកុង | ១.៥០០ | ខែ ០៦ - ខែ ១១ |
| អូរតាជូ | ១.០០០ | នេសាទមិនបាន |

ខ.៣.ប្រឡាយ

| ឈ្មោះប្រឡាយ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| ប្រឡាយស្ពុំ(ផាក់ខា) | ១០០ | ខែ៧-ខែ១០ |
| ប្រឡាយតាជុង | ៨០ | ខែ៧-ខែ១០ |
| ប្រឡាយប្រាប់ | ១៥០ | ខែ៨-ខែ១១ |

ខ.៤.អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់ថ្ម | ១៥០×៥០ | ៧.៥០០ | ២៣ | ១៣ |
| អន្លង់ស្កាតស្វា | ១៣០×៥០ | ៦.៥០០ | ១៨ | ០៨ |
| អន្លង់ស្មៅផ្អែម | ១០០×៥០ | ៥.០០០ | ១៨ | ០៨ |
| អន្លង់គោលបាក់ | ៥០×៥០ | ២.៥០០ | ១៨ | ០៨ |
| អន្លង់តាអួន | ៥០×៥០ | ២.៥០០ | ១៨ | ០៨ |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន១ អន្លង់ គឺអន្លង់ថ្ម តាមការសម្រេចរបស់មហាសន្និបាត។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ ( ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់ថ្ម | ប: ១៥០ X ទ:៥០ | ៧.៥០០ | ២៥ | ១៥ |

ឃ.ធនធានជលផល

ឃ.១.ប្រភេទត្រីៈ

ត្រីរ៉ស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្លូញ ខ្មាន់ ឆ្ពិន ប្រកែង កន្ទ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ជ្រូក កាហែ ត្រីលេញ ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឬស្សី ត្រីខ្ទឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីគ្រសក់ ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីរាហ៊ូ ត្រីក្របី ត្រីកន្ត្រង់ប្រេង ត្រីឬស្សីចេក ត្រីខ្យាថ្ម ត្រីក្តុក ត្រីខ្យាថ្ម ត្រីអន្លុង ត្រីគល់រាំង ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីអណ្តែង ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអាចម៍កុក....។

ឃ.២.ប្រភេទវារីសត្វៈ

ក្តាម ខ្យង់ ខ្ចៅ គ្រុម លៀស ពស់ កំពិស កង្កែប ហ៊ីង គីង្គក់...។

ឃ.៣.ប្រភេទសត្វបក្សី

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្អែកទឹក ក្អែកគោក...។

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិៈ

ដើមត្រែង ដើមអញ្ចាង ដើមរំចេក ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមឆ្នាទឹក ដើមក្តុល ដើមជ្រៃ ដើមព្រីង ដើមញ ដើមព្រុះទឹក ដើមទន្លាត ដើមក្របៅ ដើមចេកទុំ ដើមពោ ដើមបន្លាឃ្លេ ដើមឆ្លឹងត្រី....។

## ៤.ការធ្វើនេសាទ

ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១១២គ្រួសារ ស្មើ២២៤នាក់ ស្រី៦០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន២៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមកពីក្រៅសហគមន៍មានចំនួនស្មើ៥០នាក់ស្រី២០នាក់។

ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍ៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ / ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| មង | ម៉ែត្រ | ៧៥គ្រួសារ× ១០០ម = ៧៥.០០០ម | ៦គ្រួសារ× ១០០ម= ៦០០ម | គ្មាន | ក្រឡា២-១២ស.ម ជម្រៅ៣-៥ម | ក្រឡា២-១២ស.ម ជម្រៅ៣-៥ម | គ្មាន | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៣០គ្រួសារ× ២វង់=៦០វង់ | គ្មាន | គ្មាន | ក្រឡា១,៥-៧ ស.ម សំរុង ៣,៥-៥,៥ម | គ្មាន | គ្មាន | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ១០០គ្រួសារ× ១០០ផ្លែ = ១០.០០០ផ្លែ | ៦គ្រួសារ× ១០០ផ្លែ =៦០០ផ្លែ | គ្មាន | ផ្លែលេខ ១២-៥ | ផ្លែលេខ ១២-៥ | គ្មាន | ពេញមួយឆ្នាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| លប | គ្រឿង | ១០គ្រួសារ × ៥គ្រឿង =៥០គ្រឿង | គ្មាន | គ្មាន | មុខកាត់ ០,៣០ម ប្រវែង ១ម | | គ្មាន | ខែ៦- ខែ១១ |
| ចាន់ | គ្រឿង | ៤គ្រួសារ×៥ គ្រឿង=២០ គ្រឿង | គ្មាន | គ្មាន | មុខកាត់ ៤០ស.ម ប្រវែង១,៣ម | គ្មាន | គ្មាន | ខែ៦-ខែ១០ |

ប្រភេទទូកកាណូត

| ប្រភេទ កាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កំលាំង (សេះ) | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ |
| ទូកអេវជាប់ ម៉ាស៊ីន HONDA | ៦ | ៦ | ០ | ១០០-២០០ | ២០០-៣០០ | ០ | ៨-១៣ | ៦,៥០ | ០ |
| ទូកអុំ ចែវ | ១៥ | ០ | ០ | ១០០-៣០០ | ០ | ០ | ០ | ០ | ០ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | **១.៦៦១,០៥** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនវិស័យ

សហគមន៍នេសាទកោះឈើទាលធំ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោមៈ

- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- ធ្វើឱ្យត្រីមានការកើនឡើង
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវជំនឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីដែននេសាទ ប្រភេទឧបករណ៍នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍ កោះឈើទាលធំ | នេសាទពេញ ១ឆ្នាំជាលក្ខណៈ គ្រួសារ | មង | ១០០ម៉ែត្រ/គ្រួសារ | ៧៥គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និងអ្នកខាងក្រៅ |
| | | សំណាញ់ | ២វង់/គ្រួសារ | ៣០គ្រួសារ | |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ១០០គ្រួសារ | |
| | | លប | ៥គ្រឿង/គ្រួសារ | ៥គ្រួសារ | |
| | | ចាន់ | ៥គ្រឿង/គ្រួសារ | ៤គ្រួសារ | |
| - ប្រឡាយឈើទាល<br>- ប្រឡាយដំបង<br>- ប្រឡាយ ល្វា<br>- ប្រឡាយតាពៃ និង<br>- ប្រឡាយឬស្សី | ខែ៨ - ខែ១២ | មង | ១០០ម៉ែត្រ/គ្រសារ | ៧៥គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និងអ្នកខាងក្រៅ |
| | | សំណាញ់ | ២វង់/គ្រួសារ | ៣០គ្រួសារ | |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ១០០គ្រួសារ | |
| | | លប | ៥គ្រឿង/គ្រួសារ | ៥គ្រួសារ | |
| | | ចាន់ | ៥គ្រឿង/គ្រួសារ | ៤គ្រួសារ | |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍កោះឈើទាលធំទំហំ៣២៩ហិតា | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៧បង្គោល | -ផលិតបង្គោលព្រំ<br>-រៀបចំក្រុមចុះបោះបង្គោលព្រំ<br>-ផ្សព្វផ្សាយជាសាធារណៈ | ៣៥០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ<br>-មេឃុំ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីធ្វើពីដែក២ ផ្ទាំង | -ផលិតផ្ទាំងប៉ាណូផែនទី<br>-ចុះបោះផ្ទាំងប៉ាណូផែនទី | ៤០០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ | ២០២០ | ២០២២ |
| | ស្លាកអប់រំ៣០ | ចុះបោះស្លាកក្នុងកន្លែងនេសាទសហគមន៍ | ១២០ | គណៈកម្មការ | ២០២០ | ២០២២ |

### ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ថ្ម | ០,៧៥ | - ត្រីមេពូជ<br>- សត្វស្លាប<br>- ព្រៃលិចទឹក | - ផ្សព្វផ្សាយពីកន្លែងអភិរក្សដល់សមាជិកសហគមន៍នេសាទ<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំកន្លែងអភិរក្ស | ៥៥០ | ២០២០ | ២០២២ |

### ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើត្រូវការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងដែនសហគមន៍នេសាទកោះឈើទាលធំ | ១,៥ | ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក នឹងធ្វើទិវាលដាំព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សាការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ។ | ១.២០០ | ២០២០ | ២០២២ |

## ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទ/បរិមាណ | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន៥០គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលចិញ្ចឹមមាន់តាមបច្ចេកទេសជាក្ខណៈគ្រួសារ<br>-អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិករធ្វើទ្រុង ផ្តល់ពូជចិញ្ចឹម<br>-តាមដានត្រួតពិនិត្យជាប្រចាំ។ | ពូជក្នុងស្រុក១គ្រួសារទទួលបានមាន់៥ក្បាល សរុប២៥០ក្បាល | ៧.៥០០ | ២០២០ | ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន៥០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ។ | ពូជក្នុងស្រុក៥០ក្បាល | ១៥.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមគោតាមបច្ចេក-ទេសជាលក្ខណៈគ្រួសារចំនួន៥០គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បង្កើតគោលការណ៍<br>-ផ្តល់ពូជ<br>-ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ១៥.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន១៥គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បង្កើតគោលការណ៍<br>-ផ្តល់ពូជ<br>-ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ៤.៥០០ | ២០២០ | ២០២២ |
| ដាំបន្លែតាមបច្ចេកទេសកសិកម្មវ៉ៃយឆ្លាត ចំនួន ៤០ គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាលការដាំបន្លែជាលក្ខណៈគ្រួសារ និងអនុវត្តផ្ទាល់<br>-ផ្តល់គ្រាប់ពូជបន្លែ<br>-ត្រួតពិនិត្យនិងតាមដាន | គ្រាប់ពូជបន្លែ(ស្ពៃ ត្រកួន ត្រសក់ សណ្តែក ត្រប់) | ១២.០០០ | ២០២០ | ២០២២ |
| ធ្វើធានាគារក្របីចំនួន១៥គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>-បង្កើតគោលការណ៍សមាជិកក្រុម<br>-អនុវត្តន៍ជាក់ស្តែងជាមួយកសិករ<br>- តាមដានត្រួតពិនិត្យការថែទាំ។ | ២គ្រួសារ/ក្របីមេ១ក្បាល | ៦.០០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទ វារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ កូនត្រី | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (២០គ្រួសារ/ឆ្នាំ) | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ ធ្វើសំណាក | ២០ស្រះ ទំហំ៥ម× ១០ម | ២០.០០០ ក្បាល/គ្រួសារ | ៣៦.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| ផ្លូវគ្រួសក្រហម (២,០០០ម) ១ខ្សែរ | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យ ៥០គ្រួសារ | ១០.០០០ | ២០២០ | ២០២២ |
| លូកាត់ផ្លូវ ៥កន្លែង | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់អណ្តូងស្នប់ ៥កន្លែង | ១០.០០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ | ៧០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | | | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | | | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយក្នុងភូមិ | | | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | | | |
| | ចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយតាមភូមិ | | | |

ឃ.៣. ការងា[redacted]ប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារៈ | ចំនួន | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | | ៨ដង/១ខែ | ៤.៥០០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅសហគមន៍នេសាទ | | ២ដង/១ខែ | | ២០២០ | ២០២២ |
| ប្រេងសម្រាប់ល្បាត | | ៦០លីត្រ/ខែ | | ២០២០ | ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ | | ២០២០ | ២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ៧ អាវ | ១.០០០ | ២០២០ | ២០២២ |
| | អាវភ្លៀង | ៧ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៧ គោម | | | |
| | វិទ្យុទាក់ទង | ៧ គ្រឿង | | | |
| | កែវយឹត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ៧ អង្រឹង | | | |
| | តង់គ្របទូក ៤ម x ៦ម | ២ តង់ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១ កំប្លេ | | | |
| | ស្លាបចក្រ | ៦ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ សោរ | | | |
| | ធុងគ្របម៉ាស៊ីន | ២ឈុត | | | |
| ទិញទូកស្នាច់ម៉ាស៊ីន (១៣-១៨ សេះ) | | ២ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ដីមានស្រាប់(វណ្ណា អ៊ិត) | ១កន្លែង | ៦០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង/១ឆ្នាំ | ៣៤០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង/១ឆ្នាំ | ៣៤០ | | |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា គ្រប់គ្រងបញ្ជីស្នាម | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលអំពីច្បាប់ជលផល | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលការសរសេររបាយការណ៍ និងកំណត់ហេតុ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលសរសេរគម្រោងភាពជាអ្នកដឹកនាំ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលដោះស្រាយទំនាស់ វិធីសាស្រ្តចុះល្បាត | ១ដង/១ឆ្នាំ | ២០០ | | |
| បណ្តុះបណ្តាលច្បាប់ស្តីពីតំបន់ការពារ | ១ដង/១ឆ្នាំ | ១៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្ត | ១ដង/១ឆ្នាំ | ១.០០០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦០០ | | |
| ផ្សព្វផ្សាយដែននេសាទសហគមន៍ | ១ដង/ឆ្នាំ | ២៥០ | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ២៥០ | | |
| ផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ២៥០ | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្រ្តីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ២៥០ | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២ដង/ឆ្នាំ | ៦០០ | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ | ១ដង/ឆ្នាំ | ៦០០ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១០០ | ២០២០ | ២០២២ | - គណៈកម្មការសហគមន៍នេសាទ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប(ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកសហគមន៍ | ប្រមូលភាគទាន៥០០រៀល/ម្នាក់ | ២០២០ | ២០២២ | ៤៦ | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ប្រមូលភាគទានប្រចាំឆ្នាំក្នុង ១គ្រួសារចំនួន ២.០០០រៀល | ២០២០ | ២០២២ | ១៦៨ | |
| ភាគទានពីអ្នកមិនចូលជាសមាជិក និងអ្នកនេសាទក្រៅសហគមន៍នេសាទ | ប្រមូលភាគទានពីអ្នកមិនចូលជាសមាជិកសហគមន៍ (២៥នាក់ × ៥០.០០០រៀល/រដូវនេសាទ) | ២០២០ | ២០២២ | ៩.៣៧៥ | |
| | ប្រមូលភាគទានពីអ្នកមកពីខាងក្រៅសហគមន ៥០នាក់ × ៥០.០០០រៀល/រដូវនេសាទ | ២០២០ | ២០២២ | ១.៨៧៥ | |
| **សរុបថវិកាដែលសហគមន៍** | | | | **១១.៤៦៤** | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | **១៤៩.៦២៦** | |
| **សរុបថវិកាគ្រោងចំណាយ** | | | | **១៦១.០៩០** | |

### ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២០ | ២០២០ | ២០២២ | គណៈកម្មការ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំដោយមានការចូលរួមពីស្ត្រី និងអ្នកពាក់ព័ន្ធសំខាន់ៗ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

### ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការគ្រប់គ្រង
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះឈើទាលធំ រយៈពេល៣ ឆ្នាំ (២០២០ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និង ផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន៧បង្គោលដាក់នៅតាមព្រំប្រទល់ដែននេសាទ កោះឈើទាលធំ | - បង្គោលចំនួន៧ដើមត្រូវបានផលិត និងបានបោះនៅតាមព្រំប្រទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៣៥០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៤០០ | | ២០២០ | ២០២២ | |
| | ស្លាកអប់រំចំនួន៣០ស្លាក | ស្លាកអប់រំត្រូវបានផលិតនិងបានបោះនៅក្នុងសហគមន៍ដែននេសាទ | ១២០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់ថ្ម | - ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងសារៈប្រយោជន៍កន្លែងអភិរក្សដល់សមាជិក<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្ស | ៥៤០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការពារព្រៃលិចទឹក | - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹកក្នុងដែននេសាទ<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | -ព្រៃលិចទឹកកើនឡើងវិញ<br>-ធនធានត្រីមានការកើនឡើងវិញ | ១.២០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់[illegible]ន ថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់៥០គ្រួសារ | ៧.៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូក៥០គ្រួសារ | ១៥.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមគោ៥០គ្រួសារ | ១៥.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមក្របីតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមគោ១៥គ្រួសារ | ៤.៥០០ | | ២០២០ | ២០២២ | |
| | ដាំបន្លែតាមបច្ចេកទេសកសិកម្មវៃឆ្លាត | មានគ្រួសារដាំបន្លែ៤០គ្រួសារ | ១២.០០០ | | ២០២០ | ២០២២ | |
| | បង្កើតធនាគារក្របី | សមាជិកចូលរួមបង្កើតចំនួន១៥គ្រួសារ | ៦.០០០ | | ២០២០ | ២០២២ | |
| ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន២០គ្រួសារ | ៣៦.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | ផ្លូវគ្រួសក្រហម(២.០០០ម) ១ខ្សែរ | មានផ្លូវគ្រោះក្រហមប្រវែង២.០០០ម | ១០.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៥០បង្គន់ | ១០.០០០ | | ២០២០ | ២០២២ | |
| | លូកាត់ផ្លូវ៥កន្លែង | បានដាកលូកាត់ផ្លូវ៥កន្លែង | ១០.០០០ | | ២០២០ | ២០២២ | |
| | សាងសង់អណ្តូងស្នប់ | បានដាក់អណ្តូងស្នប់៥កន្លែង | ១០.០០០ | | ២០២០ | ២០២២ | |
